# ការសំភាសន៍របស់អ្នកមីង សុខ ឈុននី

កៈ អ្នកធ្វើការសំភាសន៍ដោយ គីម ម៉េង    ខៈ អ្នកដែលត្រូវបានគេសំភាសន៍ សុខ ឈុននី

## ការសង្ខេបរបស់អ្នកមីង សុខ ឈុននី

អ្នកមីង សុខ ឈុននី គាត់មានអាយុ ៣៥ឆ្នាំ ក្នុងឆ្នាំ ២០១៨។អ្នកមីង សុខ ឈុននី ភេទស្រីអ្នកមីង សុខ ឈុននីមានកូនចំនួន ៣ នាក់ ។អ្នកមីង សុខ ឈុននី រស់នៅភូមិ ឧញ៉ាតី កោះ ឧកញ៉ាតី ខេត្ត កណ្តាល។អ្នកមីង សុខ ឈុននី មានទីលំនៅនាពេលបច្ចុប្បន្ននៅ ភូមិ ឧកញ៉ាតី កោះ ឧកញ៉ាតី ខេត្ត កណ្តាល។

កៈ
ចឹងជាដំបូងជំរាបសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ចើញដើម្បីមានការសំភាសន៍អ្នកមីងអំពីរពង្សប្រវត្តិតតើអ្នកមីងអាយអនុញ្ញាត្តិអោយខ្ញុំបានសំភាសន៍អ្នកមីងពង្សប្រវត្តិអ្នកមីងបានដែលឬទេអ្នកមីង???

ខៈ ចាសបាន ៕

កៈ ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍អ្នកមីងគឺជាថ្ងៃទី២៣ ខែ ០៦ ( មិថុនា ) ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកមីងឈ្មោះ សុខ ឈុននី
ចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះពេញរបស់អ្នកមីងបានដែលទេអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំមានឈ្មោះថា សុខ ឈុននី៕

កៈ បាទហើយសំរាប់អ្នកមីងថាតើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយសំរាប់ឆ្នាំនឹងអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺឆ្នាំនឹងគឺខ្ញុំមានអាយុ ៣៥ ឆ្នាំហើយចាស៕

កៈ បាទសំរាប់អ្នកមីងអាយុ ៣៥
ឆ្នាំហើយចឹងខ្ញុំចង់សួរអ្នកមីងមួយថាតើសំរាប់អ្នកមីងទាំងនាមត្រកូលរបស់អ្នកមីងពេញតែម្តងហាសមានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំឈ្មោះពេញរបស់ខ្ញុំនឹងគឺមានឈ្មោះថា សុខ ឈុន លី៕

កៈ បាទហើយសំរាប់អ្នកមីងមានឈ្មោះហៅក្រៅដែលរឺទេអ្នកមីង???

ខៈ ចាសសំរាប់ហៅក្រៅរបស់ខ្ញុំនឹងគឺមានឈ្មោះថា ឈុន លី នឹងតែម្តងហាសចាស៕

កៈ
បាទអរគុណច្រើនអ្នកមីងហើយសំរាប់អ្នកមីងថាតើអ្នកមីងមានកូនចំនួនប៉ុន្មាននាក់ហើយអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំគឺខ្ញុំមានកូននឹងចំនួន ៣ នាក់ចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងមានកូនចំនួន
៣នាក់ហើយសំរាប់កូនទាំង៣នាក់នឹងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់កូនរបស់ខ្ញុំទាំង៣នាក់នឹងគឺគាត់មានឈ្មោះថា
មីនានឹងសំរាប់កូនទី១របស់ខ្ញុំ វីរៈ នឹងសំរាប់កូនរបស់ខ្ញុំទី២
ហើយសំរាប់កូនរបស់ខ្ញុំទី៣នឹងគឺគាត់មានឈ្មោះថា មៀលលា ៕

កៈ
បាទហើយសំរាប់មើលទៅកូនកូនរបស់អ្នកមីងទៅមើលទៅស្អាតស្អាតហេហេហេហេហើយសំរាប់ទីកន្លែងកំណើតរបស់អ្នកមីងមានទៅកន្លែងកំណើតនៅទីកន្លែងដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ទីកន្លែងកំណើតរបស់ខ្ញុំនឹងគឺរស់នៅចុងកោះនឹងតែម្តងហាសចាស៕

កៈ
ហើយសំរាប់អ្នកមីងរស់នៅចុងកោះនឹងមានភូមិអ្វីស្រុកអ្វីហើយនឹងខេត្តអ្វីដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់ចុងកោះនឹងគឺនៅភូមិចុងកោះកោះឧកញ្ញាតីស្រុកខ្សាច់កណ្តាលហើយនឹងខេត្តកណ្តាលចាស៕

កៈ បាទហើយសំរាប់ប្តីរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ឡាយ ចាន់ថា ៕

កៈ ហើយសំរាប់ប្តីរបស់អ្នកមីងឆ្នាំនឹងគឺគាត់មានអាយុប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខៈ ចាសសំរាប់ប្តីរបស់ខ្ញុំនឹងឆ្នាំនឹងគឺគាត់មានអាយុ ៣៧ ឆ្នាំ ហើយចាស៕

កៈ បាទហើយចឹងបានន័យថាសំរាប់ប្តីរបស់អ្នកមីងគឺគាត់ប្អូនអ្នកមីង២
ឆ្នាំមែនដែលរឺទេអ្នកមីងហើយសំរាប់ទីកន្លែងកំណើតប្តីរបស់អ្នកមីងគាត់មានទីកន្លែងកំណើតនៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ទីកន្លែងកំណើតរបស់ប្តីរបស់ខ្ញុំនឹងគឺគាត់នៅសង្កាត់ព្រែកលាភដែលនៅខាងសែនសុខនឹងហាសចាសនឹងហើយគឺជាស្រុកកំណើតរបស់គាត់នឹងហាសគឺនៅខាងព្រែកលាភនឹងតែម្តងហាសចាសហើយនឹងខណ្ឌឬស្សីកែវដែលចឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងធ្វើយ៉ាងមិចដែលទៅបានជាអ្នកមីងបានជួបជាមួយនឹងប្តីរបស់អ្នកមីងដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំនឹងបានជួបប្តីរបស់ខ្ញុំនឹងគឺយើងនឹងបានធ្វើការងារចឹងហាសហើយម្យ៉ាងទៀតនឹងគឺយើងបានជួយដោយសារតាមមិត្តភក្តិរបស់ខ្ញុំចឹងហាសចាសហើយសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់ត្រូវជាពូមិត្តភក្តិរបស់ពូរបស់ខ្ញុំចឹងហាសចាស៕

ក៖
បាទហើយសំរាប់អ្នកមីងបានស្គាល់គ្នាប៉ុន្មានឆ្នាំហើយបានអ្នកមីងបានរៀបអាពាហ៍អាពាហ៍ជាមួដែលទៅអ្នកមីង???

ខ៖
គ្នានឹងគឺខ្ញុំបានស្គាល់គ្នាជាមួយនឹងមិត្តភក្តិរបស់ខ្ញុំនឹងបានប្រហែលជា២ឆ្នាំចឹងហាសចាសហើយសំរាប់ការជួបមុខរបស់គាត់នឹងបានប្រហែល១ឆ្នាំចឹងហាសចាសហើយសំរាប់បានស្គាល់គាត់នឹងបានតាមរយះចាសទុំចឹងហាសចាសហើយនៅពេលដែលយើងបានជួបមុខគ្នាបានតែ២រឺក៏បានតែ៣ដងនោះទេចាសហើយនៅពេលដែលយើងនឹងបានជួបគ្នានឹងគឺចាស់ទុំគាត់បានសំផ្តាំអោយចឹងហាសចាសហើយសំរាប់គាត់មើលមកយើងនឹងបានស្រឡាញ់គាត់ចឹងហាសចាសក៏ប៉ុន្មានសំរាប់ម៉យខ្លួននឹងមិនទាន់បាននិយាយរកគ្នាចឹងហាសចាសហើយសំរាប់ចាសចាសនៅពេលដែលគាត់បានឃើញខ្ញុំចឹងក៏គាត់បានពេញចិត្តដែលចឹងទៅហើយសំរាប់មិត្តភក្តិនឹងគឺគាត់បាននាំទៅលេងផ្ទះចឹងក៏គាត់បានឃើញចឹងទៅហើយគាត់បានសំផ្តាំអោយកូនរបស់គាត់តែម្តងចឹងហាសចាសហេហេហេហេនិយាយទៅគ្មាននាក់ណាដែលគេបានមកសួរខ្ញុំយ៉ាងចឹងនោះទេចាសហើយនៅពេលដែលមកបានសួរខ្ញុំនឹងគឺខ្ញុំនឹងចង់ឆ្ងល់ចឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាហ៍ពិពាហ៍នឹងថាតើសំរាប់អ្នកមីងបានស្រឡាញ់គាត់ដែឡរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺស្រឡាញ់ដែលហាសហេហេហេហើយប្រសិនជាយើងនឹងមិនបានស្រឡាញ់គាត់នឹងគឺយើងមិនបានយកគាត់ធ្វើប្តីរបស់យើងនោះចាស៕

កៈ
បាទហើយចឹងសំរាប់អ្នកមីងបានស្រឡាញគាត់ដោយការពេញចិត្តមែនដែលទេអ្នកមីងបាទហើយសំរាប់នៅពេលដែលអ្នកមីងបានរៀបអាពាហ៍ពិពាហ៍នឹងថាសំរាប់អ្នកមីងបានរៀបអាពាហ៍ពិពាហ៍នឹងនៅក្នុងឆ្នាំណាដែលទៅអ្នកមីង???

ខៈ
ចាសនិយាយទៅទាល់តែខ្ញុំនឹងមើលសំបុត្ររៀបអាពាហ៍ពិពាហ៍នឹងសិនចឹងហាសចាសទាល់តែខ្ញុំនឹងបានទៅមើលសំបុត្ររៀបអាពាហ៍ពិពាហ៍នឹងហើយសំរាប់សំបុត្ររៀបអាពាហ៍ពិពាហ៍នឹងនឹងគឺខ្ញុំបានទុកដែលចឹងហាសចាស៕

កៈ
បាទហើយប្រសិនជាអ្នកមីងប្រហាក់ប្រហែលនឹងរៀបអាពាហ៍ពិពាហ៍នឹងនៅក្នុងឆ្នាំណាដែលទៅអ្នកមីង???

ខៈ ចាសនៅពេលដែលខ្ញុំនឹងបានរៀបអាពាហ៍ពិពាហ៍នឹងគឺខ្ញុំនឹងមានអាយុ
២៦ឆ្នាំចឹងហាសចាសហើយប្រសិនជាយើងនឹងបានគិតចឹងហាសគឺរៀបអាពាហ៍ពិពាហ៍នឹងប្រហែលជាបាន
១០ឆ្នាំជាងដែលចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានរៀបអាពាហ៍ពិពាហ៍នឹងបាន៥ខែនឹងគឺខ្ញុំមានកូនជាមួយនឹងគាត់ចឹងហាសចាសចឹងគឺយើងអាចនិយាយបានថាគឺយើងបានរៀបអាពាហ៍ពិពាហ៍នឹងនឹងបាន១០ឆ្នាំហើយចឹងហាសចាសចឹងប្រហែលជា២៥ឆ្នាំចឹងហាសដោយពីមកដល់លូវនឹងគឺខ្ញុំមានអាយុ៣៥ហើយចឹងហាសចាសដោយសារសំរាប់ខ្ញុំនឹងគឺខ្ញុំបានរៀបអាពាហ៍ពិពាហ៍នឹងនៅក្នុងអាយុ ៣៥ ហើយចឹងហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលរៀបអាពាហ៍ពិពាហ៍នឹងថាអ្នកមីងបានរៀបអាពាហ៍ពិពាហ៍នឹងនឹងនៅទីកន្លែងណាដែលទៅអ្នកមីង???

ខៈ
ចាសនៅពេលដែលខ្ញុំនឹងបានរៀបអាពាហ៍ពិពាហ៍នឹងគឺនៅកន្លែងផ្ទះនឹងតែម្តងហាសចាស៕

កៈ
បាទហើយនៅពេលដែលរៀបអាពាហ៍ពិពាហ៍នឹងនៅភូមិអ្វីហើយនឹងស្រុកអ្វីដែលទៅអ្នកមីង???

ខៈ ចាសនៅពេលដែលខ្ញុំរៀបអាពាហ៍ពិពាហ៍នឹងនៅក្នុងភូមិ ចុង កោះ
ស្រុកខ្សាច់កណ្តាលហើយនឹងខេត្តកណ្តាលរបស់យើងនឹងតែម្តងចឹងហាសចាស៕

ក៖
បាទហើយនៅពេលដែលរៀបអាពាហ៍ពិពាហ៍នឹងថាតើសំរាប់អ្នកមីងបានទទួលបណ្ដាលការនឹងបានចំនួនប៉ុន្មានដែលទៅអ្នកមីង???

ខ៖
ហេហេហេហាអូត្រូវសួរចឹងទៀតហើយសំរាប់ខ្ញុំនឹងគឺខ្ញុំពិបាក់នឹងឆ្លើយណាស់ចាសហើយប្រសិនជាខ្ញុំមិនបានប្រាប់បានដែលរឺទេចាសហើយសំរាប់នៅក្នុងជំនាន់នឹងគឺថាពីលូវនឹងមិនបានថ្លៃនោះទេហើយសំរាប់ជំនាន់មុននឹងគឺយើងនឹងបានទទួលបានថ្លៃចឹងហាសចាសគឺនៅក្នុងជំនាន់នឹងគឺខ្ញុំទទួលបានចំនួន ១៥០០ ចឹងហាសតែសំរាប់ជំនាន់មុននឹងគឺសំរាប់ ១៥០០
នឹងគឺលុយវាថ្លៃណាស់ចាសពីព្រោះអីនឹងសំរាប់ជំនាន់មុននឹងសំរាប់អ្នកខ្លះនឹងគឺគេបានទទួលបានតែ ៨០០រឺក៏ ៩០០រឺក៏
១០០០អីនឹងគឺអស់ហើយចឹងហាសចាសតែសំរាប់ខ្ញុំនឹងគឺខ្ញុំបានទទួលបានលុយនឹងបាន ១៥០០
ចឹងហាសចាសតែសំរាប់ម្ដាយក្មេករបស់ខ្ញុំនឹងមើលទៅកាន់គាត់គឺគាត់មានចិត្តចឹងហាសហើយសំរាប់គាត់ហើយគាត់បានស្រឡាញ់គ្រួសាររបស់ខ្ញុំដែលចឹងហាសចាសគឺគាត់បានអោយខ្ញុំនឹងបាន ១៥០០ ចឹងហាសចាស៕

ក៖ បាទហើយនៅពេលដែលអ្នកមីងបានទទួលបានបណ្ដាលការបាន ១៥០០
ចឹងថាតើប្ដូកដកគុណចែកនឹងថាតើវាបានគ្រាប់ចំនួននឹងរោងរៀបអាពាហ៍ពិពាហ៍នឹងដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅសំរាប់១៥០០នឹងគឺយើងនឹងបានសង់គេហើយនឹងបាននៅសល់នឹងគឺគ្រាប់ដែលចឹងហាសចាសហើយនៅពេលដែលយើងនឹងបានសងគេហើយចឹងគឺយើងនៅសល់ខ្លះខ្លះសំរាប់គ្រាន់បានចាយខ្លះចឹងហាសចាសហើយគឺយើងនៅសល់បាន២០០រឺក៏៣០០ចឹងហាសសំរាប់ចាយចឹងហាសចាសហើយយ៉ាងទៀតនឹងគឺយើងនឹងមិនបានជំពាក់ចឹងហាសចាសហើយនៅពេលដែលយើងនឹងមិនបានជំពាក់គេចឹងគឺយើងនឹងមិនបានពិបាក់ចិត្តចឹងហាសចាស៕

ក៖
បាទហើយចឹងខ្ញុំចង់សួរបកក្រោយបន្តិចថាតើឪពុកហើយនឹងម្ដាយរបស់អ្នកមីងមានឈ្មោះអ្វីដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា សោម ស៊ីថា
ហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ស៊ុន ធារី ចាស៕

ក៖ បាទហើយសំរាប់លោកទាំង២នាក់គាត់មានអាយុប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខ៖
ចាសសំរាប់ឪពុករបស់ខ្ញុំនឹងល្ងវនឹងគឺគាត់បានស្លាប់បាត់ហើយចឹងហាសចាសហើយសំរាប់គាត់បានស្លាប់នៅក្នុងជំនាន់ពោលពតចឹងហាសចាសហើយគាត់បានស្លាប់នៅក្នុងអាយុ
៦៣
ឆ្នាំចឹងហាសចាសហើយប្រសិនជាយើងនឹងគិតទៅគឺគាត់បានស្លាប់មុនម្តាយរបស់ខ្ញុំនឹង២ឆ្នាំចឹងហាសចាសពីព្រោះអីមកដល់ល្ងវនឹងគឺថាសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់មានអាយុ៦២ឆ្នាំនោះទេចាសហើយសំរាប់ជំនាន់ដែលឪពុករបស់ខ្ញុំនឹងបានស្លាប់នឹងគឺគាត់មានអាយុ៥៧ ឆ្នាំហើយចឹងសំរាប់ដែលគាត់បានស្លាប់នឹងគឺ
៩ឆ្នាំហើយចឹងហាសចាសហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់ប្អូនម្តាយរបស់សខ្ញុំនឹង៩ឆ្នាំចឹងហាសចាស៕

ក៖ បាទហើយចឹងបានន័យថាសំរាប់ម្តាយរបស់អ្នកមីងគឺគាត់អាយុបងឪពុករបស់អ្នកមីង៣ឆ្នាំរឺក៏៩ឆ្នាំមែនដែលទេអ្នកមីង???

ខ៖ ចាសម្តាយរបស់ខ្ញុំនឹងគឺគាត់បងប្រហែលជាបិននឹងឆ្នាំហើយចាស៕

ក៖ បាទហើយសំរាប់ឪពុករបស់អ្នកមីងគាត់បានស្លាប់ដោយសារអ្វីដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់បានស្លាប់ដោយសារតែជំងឺសួតរបស់គាត់ចឹងហាសចាសហើយនៅពេលដែលគាត់បានស្លាប់ចឹងនឹងគឺគាត់ធ្វើអ្វីចឹងហាត់ហាត់ចឹងហាសចាសហើយនៅពេលដែលយើងនឹងបានយកគាត់បានពេទ្យចឹងគឺពេទ្យបាននិយាយថាគាត់មានជំងឺសួតចឹងហាសចាសហើយសំរាប់ពេទ្យគឺគេបានបន្តនិយាយទៀតថាគឺគាត់បានដាច់សសៃឈាមខួលក្បាលចឹងហាសចាសហើយសំរាប់យើងនឹងគឺយើងបានយកគាត់ទៅពេទ្យនឹងបានតែ២យប់នោះទេគឺគាត់បានស្លាប់តែម្តងចឹងហាសចាសហើយនៅពេលដែលយើងនឹងបានយកគាត់ទៅពេទ្យនឹងគឺគាត់បានដាច់សសៃឈាមខួលក្បាលចឹងហាសចាសហើយប្រសិនជាយើងនឹងអោយគាត់បានវះនឹងក៏គាត់មិនបានរស់ដែលចឹងហាសចាសហើយនៅពេលដែលយើងនឹងបានលឺចឹងហើយចឹងគឺយើងនឹងបានយកគាត់បានទៅប្រទេសវៀតណាមទៀតដែលចឹងហាសចាសហើយនៅពេលដែលយើងនឹងបានលឺហើយចឹងយើងនឹងបាននិយាយជាមួយនឹងពេទ្យដែលថាយើងនឹងត្រូវធ្វើយ៉ាងមិចដែលទៅហើយនៅពេលដែលនឹងគឺពេទ្យបាននិយាយថាសំរាប់ជំងឺមួយនឹងទាំង ១០ នឹងមិនរស់ទាំង
១០ចឹងហាសចាសពីព្រោះអីនឹងគឺសំរាប់ជំងឺនឹងគឺវាបានដាច់សសៃឈាមធំចឹងហាសចាសចឹងហើយគ្មាននាក់បានរស់នោះទេសំរាប់ជំងឺនឹងហាសចាសដល់ពេលចឹងទៅសំរាប់គាត់បានរស់បានតែ២យប់នឹងគឺគាត់បានស្លាប់តែម្តងចឹងហាសចាសហើយសំរាបឪពុករបស់ខ្ញុំនឹងគឺគាត់បានស្លាប់មកដល់ល្ងវនឹងបាន៩ឆ្នាំហើយចឹងហាសចាសហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់មានមាឌធំខ្លាំងណាស់ហើយសំរាប់គាត់គឺគាត់មិនដែលបានឈឺអ្វីនោះទេចាសហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់នៅក្មេងដែលចឹងហាសចាសហើយសំរាប់គាត់គឺគាត់

បានធ្វើការងារដូចជាស្រែចំការចឹងហាសចាសហើយសំរាប់គាត់គឺគាត់បានហូបស្រាបានបន្តិចបន្តួចចឹងហាសនឹងសំរាប់មានកម្មវិធីចឹងហាសចាសហើយសំរាប់គាត់គឺគាត់មិនមែនជានាក់ដែលផឹកហើយនឹងប្រមឹកអ្វីនោះទេហើយនៅពេលដែលគាត់បានផឹកនឹងគឺគាត់មិនដែលបានចេទៅរករឿងអ្នកណាបានម្នាក់នោះទេចាសហើយសំរាប់គាត់ក៏គាត់មិនដែលបានវៃប្រពន្ធហើយនឹងធ្វើអំពើហិង្សាជាមួយនឹងក្រុមគ្រួសាររបស់គាត់ដែលចឹងហាសគ្រាន់តែគាត់នឹងបានហូបសំរាប់ពេលដែលគាត់បានបាយឆ្ងាញ់ចឹងហាសចាសហើយសំរាប់គាត់គឺគាត់មិនបានហូបស្រានឹងបានច្រើននោះទេតែគ្រាន់តែពេទ្យគាត់បាននិយាយថាគឺមិនមែនមកពីគាត់នឹងបានហូបស្រានោះទេគឺមកពីជំងឺរបស់គាត់តែម្តងចឹងហាសចាសហើយនិយាយទៅគឺដូចជាជំងឺហើតចឹងហាសចាស៕

កៈ
បាទនិយាយទៅស្តាយមែនទែនអ្នកមីងហើយសំរាប់គាត់អត់មានថ្នាំសំរាប់ព្យាលបាលទេមែនទេអ្នកមីង?

ខៈ
ចាសសំរាប់ជំងឺនឹងគឺខ្ញុំបានយកគាត់ទៅពេទ្យនឹងបាន២រឺក៏៣ដងចឹងហាសចាសហើយនៅពេលដែលយើងនឹងបានយកគាត់បានទៅព្យាលបាលចឹងគឺគាត់បានតែមួយធូរធូរចឹងហាសចាសហើយដល់ពេលហើយចឹងគឺសួតរបស់គាត់នឹងគឺធ្វើទុក្ខទៀតចឹងហាសចាសហើយដល់ពេលនឹងគឺគាត់បានទៅលេងផ្ទះរបស់ប្អូនរបស់គាត់ទៀតហាសគឺគាត់មិនបានឈឺនៅផ្ទះរបស់គាត់នោះទេចាសហើយនៅពេលដែលគាត់បានទៅស្រុករបស់ប្អូនរបស់គាត់នឹងគឺគាតកំពុងតែអង្គុយនៅលើអង្រឹងហើយស្រាប់តែពេលនឹងគឺគាត់បានដាច់អង្រឹងហើយនៅពេលដែលដាច់អង្រឹងនឹងគឺគាត់បានដលហើយបានអុតគូទហើយសំរាប់ពេលនឹងគឺគាត់បានដាច់សសៃឈាមហើយយគាត់ក៏បានស្លាប់ចឹងទៅហាសចាសហើយបូករួមទាំងជំងឺសួតទៀតចឹងហាសហើយយើងនឹងបានដឹកគាត់ពីស្រុករបស់គេចឹងហាសទៀតចឹងហាសចាសហើយនៅពេលដែលយើងនឹងបានដឹកគាត់បានមកចឹងគឺគាត់បានរស់នៅតែ២យប់នឹងគឺគាតក៏បានស្លាប់តែម្តងចឹងហាសចាស៕

កៈ
បាទហើយចឹងនៅពេលគាត់បានស្លាប់ចឹងសំរាប់អ្នកមីងមានអារម្មណ៍ថាស្តោតស្តាយខ្លាំងមែនដែលរឺទេអ្នកមីង???

ខៈ
ចាសនិយាយទៅគឺយើងស្តាយខ្លាំងណាស់ពីព្រោះអីនឹងគាត់មិនដែលបានធ្វើអោយកូនចៅគាត់ពិបាកចិត្តចឹងហាសចាសហើយសំរាប់គាត់ក៏មិនបានឈឺហើយនឹងមិនបានដែលបានថាមានបញ្ហាសំរាប់អោយគ្រួសាររបស់គាត់នឹងមានភាពពិបាកដែលចឹងហាសចាសហើយនឹងមានភាពស្អប់គាត់ដែលចឹងហាសចាសនិយាយទៅគឺអត់មាននោះទេពីព្រោះអីនឹងសំរាប់ប្រពន្ធហើយនឹងកូនចៅរបស់គាត់នឹងគឺថាមិនដែលបានអោយជេនោះទេហើយសំរាប់

ហៅយើងនឹងង៉ែងនឹងក៏គាត់មិនដែលបានហៅយើងនោះដែលចាសហើយសំរាប់ប្រពន្ធនឹងក៏មិនបានហៅង៉ែងង៉ែងដែលគឺហៅសុទ្ធតែខ្ញុំខ្ញុំចឹងហាសចាសហើយសំរាប់គឺគាត់ស្រឡាញ់កូនរបស់ណាស់ចាសហើយនិយាយទៅសំរាប់នាក់ស្រុកហើយនឹងអ្នកភូមិគឺគេបានស្គាយគ្រាប់គ្នាគឺគេបាននិយាយថាហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់ជាមនុស្សស្លូតចឹងហាសចាសហើយនៅពេលដែលមានបុណ្យខ្មោចរឺក៏មានបុណ្យទាននឹងគឺគាត់តែងតែទៅកំដរគេរហូតចឹងហាសចាសគឺគាត់មិនដែលបោះបង់ចោលនោះទេចាសហើយសំរាប់គាត់គឺគាត់មានញ្ញាត្តិចឹងហាសចាសហើយដល់ពេលចឹងទៅគឺគេបានស្គាយគាត់គ្រាប់គ្នាចឹងហាសចាសហើយសំរាប់ពេទ្យនឹងគឺគាត់បាននិយាយដែលថាសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់ប្រសិនជាគាត់បាននៅរស់នឹងក៏គាត់រស់មិនបានយូរដែលចឹងហាសចាសហើយប្រសិនជាគាត់នៅរស់នឹងក៏វាមានភាពវិទេនាដែលចឹងហាសពីព្រោះអីនឹងគឺគាត់មានភាពពីការហើយសំរាប់គាត់គឺគាត់បានដាច់សសៃឈាមធំចឹងហាសហើយសំរាប់គាត់ដូចខ្ញុំនឹងបាននិយាយចឹងហាសប្រសិនជាគាត់បានរស់នៅនឹងក៏គាត់មានាភាពពីការដែលចឹងហាសហើយក៏គាត់មិនបានរស់ដែលគឺគាត់នឹងបានស្លាប់ចឹងហាសចាស៕

ក៖
បាទហើយសំរាប់ឪពុករបស់អ្នកមីងគាត់បានស្លាប់អស់រយះពេលប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខ៖ ចាសសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់ស្លាប់អស់រយះពេល ៤
ហើយពីព្រោះអីនឹងសំរាប់ពេលនឹងគឺខ្ញុំនឹងបានធ្វើខួបគាត់នឹង១ឆ្នាំសំរាប់គាត់ចឹងហាសនិយាយទៅគឺថាដូចក្នុងរយះពេល១ឆ្នាំនឹងគឺខ្ញុំនឹងបានធ្វើខួបសំរាប់គាត់បានម្តងចឹងហាសចាសហើយនៅពេលដែលយើងនឹងបានធ្វើបាយហើយនឹងសំល្លរអោយគាត់ចឹងហាសចាសហើយយើងនឹងបានធ្វើតែធម្មតាចឹងហាសពីព្រោះអីនឹងគឺយើយងនឹងគ្មានលុយដើម្បីធ្វើធំដុំចឹងហាសចាសហើយសំរាប់យើងនឹងគឺយើងនឹងធ្វើបានធំដុំនឹងបានតែមួយឆ្នាំសំរាប់ដំបូងចឹងហាសហើយសំរាប់ឆ្នាំក្រោយក្រោយទៀតនឹងគឺយើងនឹងធ្វតាមធម្មតានោះទេពីព្រោះអីនឹងគឺយើងនឹងគ្មានលុយច្រើនសំរាប់ធ្វើអោយគាត់ចឹងហាសចាសហើយយើងនឹងបានធ្វើបាយហើយនឹងសំល្លនឹងបានតិចតិចនឹងអោយគាត់ចឹងទៅហាសចាសហើយសំរាប់សំល្លរនឹងបានមួយស្លាស់នឹងបានហើយនឹងបានទៅវត្ត១រឺក៏ទៅវត្ត២ចឹងហាសចាសហើយយើងនឹងបានធ្វើនៅក្នុងភូមិរបស់យើងនឹងហាសហើយសំរាប់មួយឆ្នាំមួយឆ្នាំនឹងគឺយើងនឹងមិនបានធ្វើធំដុំនោះទេចាស៕

ក៖
បាទហើយអរគុណច្រើនអ្នកមីងហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើសំរាប់ស្រុកកំណើតរបស់ឪពុករបស់អ្នកមីងហើយនឹងម្តាយរបស់អ្នកមីងគាត់ទាំង២នាក់មានស្រុកកំណើតនឹងនៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ម្ដាយរបស់ខ្ញុំនឹងកាល់ដំបូងនឹងគឺគាត់បានរស់នៅស្រុកព្រៃកតាមៀកចឹងហាស ចាសហើយនឹងភូមិព្រៃកតាមៀកហើយនឹងខេត្តកណ្ដាលរបស់យើងនឹងហាសចាសហើយ សំរាប់ស្រុកកំណើតរបស់ឪពុករបស់ខ្ញុំនឹងគឺគាត់បានរស់នៅស្រុកនឹងតែម្ដងហាសចាស ហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងនៅពេលដែលគាត់បានរៀបអាពាហ៍ពិពាហ៍នឹងគឺលោកយាយរបស់ខ្ញុំនឹងគឺគាត់បានយកមករស់នៅនឹងស្រុកនឹងតែម្ដងចឹងហាសពីព្រោះអីនឹងគឺសំរាប់ម្ដាយរបស់ខ្ញុំនឹងអត់មានផ្ទះនៅចឹងហាសហើយសំរាប់កូនរបស់គាត់នឹងគឺកូនរបស់គាត់សុទ្ធតែប្រុស៥នាក់ចឹងហាសចាសហើយដល់ពេលនឹងគឺគាត់បានយកមករស់នៅនឹងតែម្ដងទៅហើយគាត់យកមលមើលថៃពីព្រោះអីនឹងគឺគាត់ស្រឡាញ់ពួកគាត់ដែលចឹងហាសចាស៕

ក៖
បាទហើយចឹងសំណួរខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើសំរាប់អ្នកមីងកាល់អ្នកមីងនៅក្មេងក្មេងអីនឹងថាតើអ្នកមីងមានបានរៀនសូត្ររឺក៏បានសិក្សាដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងកាល់ដែលខ្ញុំនឹងបាននៅពីក្មេងនឹងគឺខ្ញុំបានរៀនសូត្រដែលតាហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងបានរៀនបានថ្នាក់ទី ១០
ដែលចឹងហាសចាសតែសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងបានឈប់ចឹងហាសពីព្រោះអីនឹងនៅពេលដែលខ្ញុំនឹងបានឃើញក្រុមគ្រួសាររបស់ខ្ញុំនឹងពិបាក់ចឹងទៅគឺខ្ញុំនឹងក៏បានរត់ធ្វើការងារនៅក្នុងរោងចក្រចឹងហាសចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងបានធ្វើការងារនៅរោងចក្រនឹងបាន៨ឆ្នាំហើយនៅពេលធ្វើការងារបាន៨ឆ្នាំហើយចឹងខ្ញុំក៏បានរៀបអាពាហ៍ពិអាហ៍ជាមួយនឹងប្ដីរបស់ខ្ញុំចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានធ្វើការងារនឹងគឺខ្ញុំនឹងបានទទួលប្រាក់៤៥
ចឹងហាសហើយសំរាប់ខ្ញុំនឹងគឺមើលទៅច្រើនដែលចឹងហាសសំរាប់ជំនាន់នឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានឃើញគាត់ពិបាក់ចឹងគឺខ្ញុំនឹងក៏សំរេចចិត្តនឹងទៅធ្វើការងារនឹងតែម្ដងចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានឈប់នឹងគឺខ្ញុំនឹងបានទៅជួយធ្វើការងារចំការរបស់គាត់ចឹងហើយខ្ញុំនឹងក៏បានទៅធ្វើការងារហើយសំរាប់ខ្ញុំនឹងបានរៀនបានថ្នាក់ទី ១០ ចឹងហាសចាស៕

ក៖ បាទហើយសំរាប់អ្នកមីងបានឈប់រៀននឹងនៅឆ្នាំណាដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងបានឈប់រៀននឹងនៅឆ្នាំណាទេគឺខ្ញុំនឹងមិនបានចាំនោះទេពីព្រោះអីនឹងនៅពេលដែលខ្ញុំនឹងបានឈប់រៀននឹងគឺថាខ្ញុំមានអាយុ ១៦ ឆ្នាំ
ហើយនៅពេលដែលខ្ញុំនឹងបានរៀនបានថ្នាក់ទី ១០
នឹងគឺខ្ញុំនឹងបានចូលរៀននឹងតាំពីខ្ញុំនឹងមានអាយុ ៦ ឆ្នាំចឹងហាសចាស៕

កៈ
បាទហើយនៅពេលដែលអ្នកមីងបានរៀននឹងថាតើអ្នកមីងគឺជាសិស្សពូកែរឺក៏ជាសិស្សមធ្យមរឺក៏ជាសិស្សខ្សោយឬក៏យ៉ាងមិចដែលទៅអ្នកមីង???

ខៈ សំរាប់ជំនាន់នឹងគឺខ្ញុំជាសិស្សមធ្យមចឹងហាសចាស៕

កៈ បាទហើយសំរាប់អ្នកមីងរៀនបានជាប់លេខបានប៉ុន្មានដែលទៅ???

ខៈ ចាសសំរាប់ខ្ញុំនឹងរៀនបានលេខ ៨ រឺក៏ លេខ ៧ អីនឹងហាសចាស៕

កៈ
បាទហើយសំរាប់សិស្សនៅក្នុងមួយថ្នាក់នឹងមានសិស្សនឹងចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង???

ខៈ ចាសសំរាប់នៅក្នុងមួយថ្នាក់នឹងគឺមានសិស្សនឹង ២៨ រឺក៏ ២៩
នាក់ចឹងហាសចាសនិយាយទៅគឺសិស្សតិចដែលចឹងហាសពីព្រោះអីនឹងនៅក្នុងជំនាន់នឹងគឺគ្មានសូវមានសិស្សច្រើននោះទេចាសសំរាប់ជំនាន់នឹងគឺសំរាប់អ្នកដែលបានរៀនបានថ្នាក់ទី ៣ រឺក៏ទី ៤
នឹងគឺពួកគាត់នឹងធំធំអស់ហើយចឹងហាសចាសគឺដូចល្ងវនឹងនោះទេចាសហើយសំរាប់ជំនាន់នឹងគឺខ្ញុំនឹងបានរៀនបានថ្នាក់ទី១០នឹងសំរាប់ជំនាន់នឹងសិស្សនឹងគឺគេបានរៀននឹងពូកែពូកែចឹងហាសចាសហើយសំរាប់ជំនាន់នឹងគឺគេបានខំរៀនចឹងហាសមិនដូចល្ងវនឹងគឺក្មេងល្ងវនឹងបានដើរលេងច្រើនចឹងហាសចាសហើយនៅពេលដែលយើងនឹងបានទៅរៀននឹងគឺបានទៅរៀននៅវិទ្យាល័យព្រៃកល្ងងនឹងដែលចឹងហាចាសហើយសំរាប់កន្លែងនឹងមានតែបឋមចឹងហាសនៅជំនាន់នឹងហាសចាស៕

កៈ
បាទហើយចឹងសំរាប់មុខវិជ្ជាមួយណាដែលអ្នកមីងបានរៀនពូកែជាងគេនៅក្នុងជំនាន់នឹងអ្នកមីង???

ខៈ
ចាសសំរាប់ជំនាន់ដែលខ្ញុំនឹបានរៀននឹងគឺមានវិទ្យាសាស្រ្តហើយនឹងភូមិវិជ្ជាហើយនិយាយទៅអោយតែជាអក្សរនឹងគឺខ្ញុំរៀនបានពូកែជាងគេចឹងហាសចាសហើយសំរាប់គណិតវិជ្ជានឹងគឺមិនបានជាសូវពូកែនឹងគេនោះទេចាសហើយសំរាប់គណិតវិជ្ជានឹងគឺវាមានភាពវញ៉េវញ៉ៃជាងគេណាស់ចាសហេហេហេហើយនិយាយទៅគឺខ្ញុំមិនបានចេះសំរាប់មុខវិជ្ជានឹងតែម្តងហើយប្រសិនជាគេបានបោកខ្ញុំនឹងគឺបោកស្រួលណាស់សំរាប់ខ្ញុំចឹងហាសចាសមែនហាសពីព្រោះអីនឹងប្តីរបស់ខ្ញុំនឹងគឺគាត់បាននិយាយថានៅពេលដែលយើងនឹងបានទៅណាមកណាហើយគេបានសួរពីប្រវត្តរបស់យើងនឹងគឺថាហើយកុំទុក្ខចិត្តគេហើយសំរាប់ខ្ញុំនឹងគឺមិនជាសូវជាចេះកហុសគេនោះទេគឺនិយាយទៅតាមត្រង់ចឹងហាសចាសហើយសំរាប់គាត់បាន

ស្ដីអោយខ្ញុំចឹងហាសហើយប្រសិនជាមានអ្នកណាដែលមកសួរអីនឹងកុំអោយខ្ញុំនឹងបានជឿរគេអោយសោះអីពីព្រោះអីនឹងគឺថាគឺមានមនុស្សនឹងបោកច្រើនហើយសំរាប់លូវនឹងគេជិតបោះឆ្នោតទៀតចឹងចឹងហើយកុំអោយខ្ញុំនឹងសួរជឿរពេកចឹងហាសចាសហើយនិយាយទៅគឺគាត់មិនជាសូវចូលចិត្តអីចឹងហាសចាសហើយប្រសិនគាត់បានមកហើយបានឃើញចឹងហើយគឺគាត់ក៏មិនជាសូវចូលចិត្តដែលចឹងហាសចាសចឹងហើយបានជាខ្ញុំនឹងសួរថាសំរាប់លោកគ្រូនឹងបានមកនឹងមករកអ្វីដែលចឹងហាសចាសពីព្រោះអីនឹងវាជារដូវបោះឆ្នោតចឹងគឺខ្ញុំនឹងចេះតែខ្លាចចឹងទៅចាស៕

ក៖
បាទហើយចឹងសំរាប់ពួកយើងនឹងគឺយើងបានមកនឹងគឺសុទ្ធតែល្អល្អចឹងទេបាទហេហេហេហេបាទហើយចឹងខ្ញុំចង់សួរទៀតថាតើនៅពេលដែលអ្នកមីងបានរៀននឹងថាតើអ្នកមីងមានមិត្តភក្ដិណាដែលសិទ្ធស្នាលដែលគាត់បានរៀនជាមួយនឹងអ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅមានដែលតាសំរាប់មិត្តភក្ដិរបស់ខ្ញុំកាល់ដែលយើងនឹងបានរៀនជាមួយនឹងគ្នាចឹងហាសចាសមាន២នាក់ដែលហើយសំរាប់មិត្តភក្ដិរបស់ខ្ញុំនឹងគឺគេបានមានគ្រួសារអស់ហើយចឹងហាសចាសហើយសំរាប់ម្នាក់នឹងគឺគេបានធ្វើការងារនឹងជាពេទ្យហើយសំរាប់ម្នាក់ទៀតគឺគេបានរកស៊ីចឹងហាសចាសហើយសំរាប់មិត្តភក្ដិរបស់ខ្ញុំនឹងហាសគឺគេមានរៀនចប់ថ្នាក់ទី ១២ ហើយសំរាប់ខ្ញុំនឹងវិញគឺខ្ញុំបានឈប់រៀននៅថ្នាក់ទី ១០ នឹងហើយហើយនៅពេលដែលគេបានរៀនចប់ថ្នាក់ទី ១២ ហើយគឺគេបានរៀនបន្តរៀនទៀតរហូតគេបានធ្វើការងារជាផ្នែកទេព្យរហូតមកដល់លូវនឹងហាសចាស៕

ក៖ បាទហើយចឹងសំរាប់សព្វថ្ងៃនឹងថាតើពួកគាត់នៅតែរាប់អានអ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺយើងនឹងនៅតែរាប់គ្នាចឹងហាសចាពីព្រោះអីនឹងនៅពេលដែលមានកម្មវិធីអីនឹងគឺយើងតែងតែតេហៅរកគ្នាដែលចឹងហាសចាសហើយប្រសិនជាយើងនឹងអោយស្និតស្នាលដូចកាល់ពីមុនអីនឹងគឺយើងអត់មាននោះទេពីព្រោះអីនឹងគឺយើងទាំងអស់គ្នានឹងសុទ្ធតែមានគ្រួសារគ្រាប់គ្នាហើយចឹងហាសចាសហើយសំរាប់លូវនឹងគឺយើងធម្មតានោះទេចាស៕

ក៖
បាទចឹងបានន័យថាទាល់តែមានពិធីរឺក៏មានបុណ្យអីនឹងបានអ្នកមីងបានខលហៅមិត្តភក្ដិរបស់អ្នកមីងមែនដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺយើងរាប់គ្នារាល់ថ្ងៃចឹងដែលហាសហើយសំរាប់មានបុណ្យរឺក៏មានកម្មវិ

ធីអីនឹងបានយើងនឹងបានហៅគ្នាចឹងហាសចាសហើយប្រសិនជាយើងនឹងអោយរាប់អានគ្នាដូចរាល់ថ្ងៃនឹងគឺមិនបាននោះទេបាទពីព្រោះអីនឹងគឺយើងនឹងរវល់រៀងខ្លួនចឹងហាសចាសហើយម្យ៉ាងទៀតគឺគេមានដែលចឹងហាសគឺគេមិនសូវជារាប់អានយើងដែលចឹងហាសចាសហើយម្យ៉ាងទៀតនឹងគឺគាត់មានគ្រួសារហើយនឹងមានកូនរៀងរៀងខ្លួនចឹងហាសចាស៕

កៈ
បាទហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើនៅពេលដែលអ្នកមីងរៀននៅសាលារៀននឹងថាតើសាលារៀននឹងមានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំគឺខ្ញុំបានរៀននៅសាលាវិទ្យាល័យព្រែកលួង៕

កៈ បាទហើយសំរាប់សាលារៀនរបស់អ្នកមីងនឹងគឺនៅម្តុំណាដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់សាលារៀនរបស់ខ្ញុំនឹងគឺនៅម្តុំក្រោយម្ខាងយើងនឹងហាសហើយសំរាប់ជំនាន់នឹងគឺគេមិនទាន់មានអនុវិទ្យាល័យនូវឡើងនោះទេនឹងសំរាប់ជំនាន់មុននឹងហាសហើយសំរាប់មកដល់នឹងគឺគេមានអនុវិទ្យាល័យហើយចាសហើយសំរាប់ជំនាន់នដែលខ្ញុំបានរៀននឹងគឺខ្ញុំនឹងបានឆ្លងទូតនឹងទៅរៀនចឹងហាសចាសហើយខ្ញុំបានឆ្លងទូតដរចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានឆ្លងទូកហើយចឹងគឺខ្ញុំបានបន្តដើរទៅរៀននៅសាលារៀនរបស់ខ្ញុំទៀតចា៕

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងទៅរៀននឹងសំរាប់អ្នកមីងគ្មានអ្វីសំរាប់ជិះទៅរៀននោះទេមែនដែលទេអ្នកមីង???

ខៈ
ចាសសំរាប់ជំនាន់របស់ខ្ញុំនឹងគឺនៅពេលដែលខ្ញុំបានដើរទៅរៀននឹងគឺគ្មានអ្វីនឹងជិះនោះទេគឺដើរទៅរៀនតែម្តងហើយសំរាប់យើងនឹងគឺយើងនឹងបានដើរតែម្តងហើយនៅពេលដែលខ្ញុំនឹងបានទៅរៀននឹងគឺខ្ញុំបានទៅរៀនបន្ថែមទៀតហើយសំរាប់ជំនាន់នឹងគឺថាគេមានភាសាអង់គ្លេសចឹងហាសហើយសំរាប់សាលារៀនដែលខ្ញុំនឹងបានរៀននឹងគឺថាគេក៏មានការហាត់កីឡានឹងធម្មតាដែលចឹងហាសចាសហើយនៅពេលដែលយើងនឹងបានទៅរៀននឹងពេលព្រឹកក៏យើងនឹងបានដើរហើយនៅពេលដែលយើងនឹងបានមកវិញនឹងក៏បានដើរមកផ្ទះដែលចឹងហាសចាសហើយសំរាប់ជំនាន់នឹងគឺយើងបានដើរហើយគ្មានអ្វីជិះនោះទេហើយសំរាប់លូវនឹងមិនដូចក្មេងលូវនឹងនោះទេគេមានអ្វីសំរាប់ជិះចឹងហាសចាសហើយសំរាប់ជំនាន់នឹងគឺគេបានលុយសំរាប់ទិញកង់សំរាប់ជិះទៅរៀនហើយសំរាប់យើងនឹងគ្មានលុយនឹងទិញកង់នឹងគឺយើងនឹងបានដើរទៅរៀនចឹងទៅហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានដើរទៅរៀននឹងសំរាប់អ្នកមីងបានប្រើរយះពេលប៉ុន្មានដែលបានដើរទៅដល់សាលារៀនដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំនឹងបានទៅរៀននឹងគឺខ្ញុំបានដើរផ្លូវកាត់ចឹងហាសចាសហើយយើងនឹងបានដើរកាត់តាមអូរចឹងទៅហើយប្រសិនចជាយើងដើរកាត់តាមភូមិនឹងគឺមានរយះពេលនឹងឆ្ងាយចឹងហាសចាសហើយយើងនឹងក៏បានដើរតាមវត្តព្រែកលួងដែលតាមផ្លូវនឹងគឺដើរតាមក្បាលកោះរបស់យើងនឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់គ្មានអ្វីសំរាប់ជិះនោះទេសុទ្ធចិត្តដើរទៅរៀនសំរាប់មួយថ្ងៃនឹងគឺយើងត្រូវចំណាយពេល២ម៉ោងចឹងទៅបានទៅដល់សាលារៀនរបស់អ្នកមីងមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅនៅពេលដែលយើងនឹងបានដើរទៅរៀននឹងគឺយើងបានឆ្លងដរហើយនៅពេលដែលយើងនឹងបានទៅរៀននឹងបានយឺតចឹងគឺគ្រូគាត់មិនបានថាអ្វីនោះទេសំរាប់យើងចឹងហាសចាសពីព្រោះអីនឹងគឺយើងនឹងបានឆ្លងទឹកចឹងហាសចាសហើយសំរាប់ផ្លូវដែលជាប់នឹងក៏គ្រូគាត់ពិន័យយើងដែលចឹងហាសចាសហើយប្រសិនជាយើងនឹងបានឆ្លងទឹកនឹងគឺគ្រូបានអនុគ្រោះអោយយើងចឹងហាសចាសហើយសំរាប់អ្នកដែលបានឆ្លងទឹកគឺគេមិនបានថាអ្វីនោះទេចាសនិយាយទៅគឺគ្រូមិនសូវជាថាអ្វីនោះទេនៅពេលដែលយើងនឹងបានទៅរៀនយឺតចឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានទៅរៀនចឹងសំរាប់អ្នកមីងមានម្ហូបសំរាប់ហូបដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅនៅដែលខ្ញុំនឹងបានទៅរៀននឹងគឺខ្ញុំបានហូបបាយពីផ្ទះហើយចឹងទៅហើយម្ដាយរបស់ខ្ញុំនឹងគឺគាត់បានដាក់អោយទៀតចឹងហាសចាសហើយយើងនឹងបានមានបង្អែមហើយមានដូចជានុំប៉ាងអីចឹងទៅហាសចាសហើយសំរាប់ជំនាន់ដូចថាក្មេងនៅជំនាន់នឹងគឺក្មេងមិនសូវជាចេះចាយលុយនោះទេចាសហើយសំរាប់ភាគច្រើននឹងគឺម្ដាយបានអោយលុយនឹងបានតិចតិចចឹងទៅហើយសំរាប់ពេលខ្លះនឹងគឺយើងនឹងមិនបានចាយផងចឹងហាសចាសហើយសំរាប់ជំនាន់នឹងគឺថាលុយមានតំម្លៃថ្លៃចឹងហាសចាសហេហេហេហេ៕

ក៖
បាទហើយសំរាប់អ្នកមីងនៅពេលដែលអ្នកមីងបានរៀននឹងនៅក្នុងឆ្នាំណាដែលទៅអ្នកមីង
???

ខ៖ ចាសនៅពេលដែលខ្ញុំនឹងបានរៀននឹងគឺនៅក្នុង
១៩៩០ប៉ុន្មាននោះទេយើងគិតមើលទៅហើយសំរាប់ខ្ញុំនឹងគិតទៅគឺមិនទាន់បានចូល ឆ្នាំ
២០០០ នោះទេចាសហើយសំរាប់មកដល់លូវនឹងគឺយើងបានចូលឆ្នាំ ២០១៨
ហើយចឹងហាសចាសហើយសំរាប់ខ្ញុំនឹងគឺបានឈប់រៀនអស់រយះពេល
១០ឆ្នាំហើយចឹងហើយនិយាយទៅចូលខ្ទង់ ២០០៩
រឺក៏២០១០ដែលចឹងហាសចាសនិយាយទៅប្រហែលជាបិននឹងហើយចាសហើយសំរាប់ខ្ញុំនឹងគឺបានឈប់រៀនយូរហើយចាសហើយសំរាប់ខ្ញុំបានឈប់រៀនតាំងពីអាយុ ១៦ ឆ្នាំ
មកម្លេះចឹងហាសចាសហើយមកដល់លូវនឹងគឺខ្ញុំបាន ៣០
ឆ្នាំជាងហើយចឹងចាសនឹងហើយគឺខ្ញុំបានឈប់រៀននៅក្នុងឆ្នាំ ២០០៨
រឺក៏២០០៩ហើយចឹងហាសចាស៕

ក៖ បាទហើយសំរាប់ជំនាន់នឹងគឺខ្ញុំទើបតែរៀនបានថ្នាក់ទី ៣ រឺក៏ទី៤ចឹងហាសចាស៕

ខ៖
ចាសនិយាយទៅសំរាប់អ្នកដែលបានរៀននៅក្នុងជំនាន់របស់ខ្ញុំនឹងគឺគេបានរៀនទេព្យរៀនអីអស់ហើយចឹងហាសចាសហើយនិយាយទៅគឺច្រើនណាស់មានរហូតដល់២ជំនាន់មេសចឹងហាសចាសហើយសំរាប់ក្មេងក្មេងជំនាន់លូវនឹងគឺថា២ជំនាន់ហើយចឹងនិយាយទៅតាំងពីយើងបានចាយលុយជំនាន់
២០រមកម្លេះចឹងហាសចាសហើយសំរាប់លុយ២០រនឹងគឺយើងនឹងមិនបានចាយអស់ទាំង២០រនឹងនោះទេគឺយើងបានចាយលុយនឹងនៅសល់១០រទៀតចឹងហាសចាសហើយនៅពេលដែលយើងនឹងនៅសល់លុយនឹងគឺយើងនឹងបានទិញនុំបានមកផ្ញើរមកអោយប្អូនសំរាប់ហូបទៀតចឹងហាសចាសនឹងសំរាប់ជំនាន់នឹងហាសចាសហើយសំរាប់លុយ២០រនឹងគឺមានតំម្លៃតែម្តងហើយសំរាប់ការទិញបង្អែមនឹងមួយចាននឹងអស់តែ៥រនោះទេហើយយើងនៅសល់១៥រអីចឹងរឺក៏នៅសល់១០រអីចឹងទៅគឺខ្ញុំបានទិញនុំមកផ្ញើរអោយប្អូនរបស់ខ្ញុំនឹងបានរាល់ថ្ងៃហើយមិនដែលថាអត់មាននោះទេគឺបានផ្ញើរម្តាយហើយនឹងបានផ្ញើរឪពុករបស់ខ្ញុំចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានមកដល់ចឹងទៅគឺខ្ញុំបានឃើញគាត់បានធ្វើចំការគឺខ្ញុំបានចូលទៅចំការដើម្បីជួយគាត់ចឹងទៅហើយសំរាប់ជំនាន់នៅពេលដែលយើងនឹងធ្វើចំការនឹងគឺថាសំរាប់ជំនាន់នឹងគឺគេបានធ្វើចំការគ្រាប់គ្នាចឹងហាសចាសហើយសំរាប់ស្រុកណាក៏គេបានធ្វើចំការដែលចឹងហាសចាស៕

ក៖ បាទហើយសំរាប់ជំនាន់នឹងសំរាប់លុយ
២០រនឹងគឺខ្ញុំបានធ្លាប់បានឃើញបានម្តងចឹងហាសហេហេហេហេ៕

ខ៖ ចាសនិយាយទៅសំរាប់ជំនាន់នឹងលុយ
២០រនឹងគឺវាមានតំម្លៃណាស់ណាស់ចាសហើយសំរាប់២០រនឹងប្រសិនជាយើងនឹងទៅរៀនឹងគឺវាគ្រាន់ហើយចឹងហាសចាសហើយសំរាប់ថ្ងៃណានឹងគឺយើងបានហូបបាយកក់ហើយយើងទៅរៀនចឹងហាសចាសនិយាយទៅសំរាប់ក្មេងជំនាន់មុននឹងគឺគេមានភាពតស៊ូរណាស់ក្នុងការរៀនសូត្រនឹងហាសចាសហើយគឺគ្មានចេះដើរលេងអ្វីនោះទេចាសគឺគេគិតតែពីរៀនចឹងហាសចាស៕

ក៖
បាទហើយចឹងអរគុណច្រើនអ្នកមីងសំរាប់ការផ្តល់ពត័មានលំអិតការសិក្សារបស់អ្នកមីងហោហោហោហើយចឹងខ្ញុំចង់សួរអ្នកមីងមួយថាតើសំរាប់ជំនាន់ពោលពតវិញថាតើអ្នកមីងបានរស់នៅទីកន្លែងណាដែលទៅអ្នកមីងហើយនៅភូមិអ្វីហើយនឹងស្រុកអ្វីដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំគឺខ្ញុំមិនទាន់នៅក្នុងជំនាន់ពោលពតនោះទេពីព្រោះអីនឹងកាល់ដែលនៅក្នុងជំនាន់ពោលពតនឹងគឺម្តាយរបស់ខ្ញុំនឹងគឺទើបតែទំងន់ខ្ញុំនោះទេចាសហើយនៅពេលដែលគាត់បានចេញបែកពីពោលពតចឹងហាសចាសហើយនៅពេលដែលចូលបែកអស់ចឹងទៅនៅពេលដែលគេបានជួយរំដោះអស់ចឹងទៅគឺម្តាយរបស់ខ្ញុំនឹងគឺគាត់ទើបតែទំងន់នោះទេចាសហើយប្រសិនជាជំនាន់បងស្រីរបស់ខ្ញុំនឹងបានគាត់ទាន់នៅក្នុងជំនាន់ពោលពតចឹងហាសចាសហើយសំរាប់មកដល់ខ្ញុំនឹងដល់តាពេលដែលគេបានរំដោះអីហើយអីហើយចឹងទៅបានខ្ញុំនឹងបានកើតចេះមកចឹងហាសចាសបានម្តាយរបស់ខ្ញុំនឹងគឺគាត់បានទំងន់ខ្ញុំចឹងចាសនិយាយទៅគឺខ្ញុំមិនទាន់នោះទេចាស៕

ក៖
បាទហើយចឹងបានន័យថាសំរាប់អ្នកមីងគឺមិនទាន់នៅក្នុងជំនាន់ពោលពតនោះទេមែនដែលទេអ្នកមីងចឹងបានន័យថានៅពេលដែលបានរំដោះហើយបានអ្នកមីងបានកើតមកមែនដែលទេអ្នកមីង???

ខ៖ ចាសគឺខ្ញុំមិបានទាន់កើតនៅក្នុងជំនាន់ពោលពតនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងកើតអត់ទាន់នៅក្នុងជំនាន់ពោលពតចឹងហើយសំរាប់អ្នកមីងនៅពេលដែលអ្នកមីងបានដឹងថាគេបានជួយរមដោះនៅក្នុងជំនាន់ពោលពតនឹងហើយសំរាប់អ្នកមីងមានដឹងទេថាគេបានជួយរំដោះនៅក្នុងឆ្នាំណាដែលរឺទេអ្នកមីង???

ខ៖
ចាសនិយយាទៅគឺខ្ញុំមិនសូវជាចាំដែលចឹងហាសចាសពីព្រោះអីនឹងគឺខ្ញុំនៅក្នុងជំនាន់នឹងគឺខ្ញុំនៅក្មេងដែលចឹងហាសចាសហើយសំរាប់ពីមុននឹងគឺមាននាក់ដែលប្រាប់ខ្ញុំដែលតែមកដល់លូវនឹងគឺខ្ញុំបានភ្លេចអស់ហើយចឹងហាសចាសហើយសំរាប់ខ្ញុំមិនបានដឹងថាគេបានរំ

ដោះនៅក្នុងឆ្នាំណានោះទេនិយាយដូចជានៅក្នុង ១៩៧៩
នឹងហើយនៅពេលដែលខ្ញុំបានរៀននឹងគឺគ្រូគាត់បានប្រាប់ខ្ញុំដែលចឹងហាសចាសនិយាយទីគឺខ្ញុំមិនទាន់នៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំមិនបានចាំនោះទេចាសតែសំរាប់ចាសចាសបានគាត់ចាំចឹងហាស៕

កៈ
បាទហើយចឹងសំរាប់អ្នកមីងមានបានចាំអំពីពត័មានអំពីឪពុកហើយនឹងម្តាយរបស់អ្នកមីងបានខ្លះដែលរឺទេអ្នកមីងដែលគាត់បានឆ្លងកាត់នៅក្នុងជំនាន់ពោលពតខ្លះខ្លះគាត់ដែលបានប្រាប់អ្នកមីងដែលរឺទេអ្នកមីង???

ខៈ
ចាសសំរាប់គាត់បានប្រាប់ដែលថាគាត់បានមានភាពពិបាកខ្លះដែលចឹងហាសដែលគាត់បាននៅក្នុងជំនាន់ពោលពតនឹងហាសចាហើយសំរាប់ជំនាន់នឹងគឺគេបានយកគាត់ទាំង២នាក់យកទៅបាញ់ចោលចឹងហាសហើយសំរាប់ពេលនឹងគឺគេបានស្គាល់គេចឹងគឺគេបានដោះលេងគាត់ហើយគាត់បានរួចខ្លួនហើយសំរាប់ពេលគឺគេបានលោងគាត់បានទៅមើលកុងចឹងហាសចាសហើយនៅពេលគេបាននិយាយចឹងហើយគឺគេបានអោយយើងនឹងបានរៀបចំខ្លួនអោយរួចជាស្រេចចឹងហាសចាសហើយដល់ពេលហើយចឹងទៅគឺគេបានអោយគាត់គឺគេបានយកឪពុកហើយនឹងម្តាយរបស់នឹងយកទៅសំលាប់ចោលហើយចឹងហាសដែលគគាត់ជាឪពុកហើយនឹងម្តាយខាងរបស់គាត់នឹងហាសចាសនិយាយទៅគឺដូចជាគេបានយកពីយើងទៅចឹងហាសចាស៕

កៈ
បាទហើយចឹងគាត់មានបានប្រាប់គាត់បន្ថែមទៀតដែលរឺទេដែលគេបានអោយគាត់ទាំង២នាក់បានធ្វើការងារដែលពិបាក់ពិបាក់ដែលនៅក្នុងជំនាន់ពោលពតចឹងហាសថាតើមានដែលរឺទេដែលមានដូចជាការស្ទុងស្រូវដែលមានភាពពិបាក់ដែលរឺទេអ្នកមីង???

ខៈ
ចាសសំរាប់ជំនាន់នឹងគឺឪពុករបស់ខ្ញុំនឹងគឺគាត់គឺជាមេសហាករចឹងហាសចាសហើយគាត់គឺជាអ្នកមើលការខុសត្រូវគេចឹងហាសចាសហើយនិយាយទៅដូចថាគាត់ជាមេអីចឹងហាសចាសហើយគាត់ត្រូវជាមួយនឹងគេចឹងហើយសំរាប់គាត់និយាយទៅគឺគាត់ជាមេសន្តិសុខភូមិចឹងហាសនៅក្នុងជំនាន់នឹងហាសចាស៕

កៈ
បាទហើយចឹងបានន័យថាសំរាប់ជំនាន់នឹងសំរាប់ឪពុករបស់អ្នកមីងគាត់គឺជាមេសន្តិសុខមែនដែលទេអ្នកមីង???

ខៈ
ចាសនិយាយទៅសំរាប់ជំនាន់នឹងឪពុករបស់ខ្ញុំគេអោយគាត់ធ្វើការងារមើលការខុសត្រូវ

ហើយនឹងមើលអ្វីផ្សេងផ្សេងដែលនៅកន្លែងធ្វើម្ហូបចឹងទៅហាសចាសដូចជាចឹងសំរាប់ខ្ញុំមិនសូវជាចាំដែលចឹងហាសចាសហើយនៅពេលដែលយើងធ្វើបាយធ្វើទឹកចឹងគឺយើងតែងតែបានចឹងហាសចាសហើយនៅពេលដែលគាត់បានធ្វើការងារស្មុងស្រូវស្មុងអីនឹងដូចលក្ខណាថាយើងមិនមែនបានអ្វីហូបតែម្តងនឹងគឺមិនមែននោះទេដូចថាឪពុករបស់ខ្ញុំនៅពេលដែលគាត់បានធ្វើខាងមនម្ហូបអីចឹងទៅគឺគាត់បានយកបានយកម្ហូបទាំងអស់នឹងអោយប្រពន្ធហើយនឹងម្តាយចឹងទៅហាសចាស៕

កៈ

បាទចឹងបាននូថាសំរាប់ជំនាន់នឹងឪពុករបស់អ្នកមីងគាតគឺជាអ្នកកាន់ខាងម្ហូបកាល់ដែលគាត់នៅក្នុងជំនាន់ពោលពតមែនដែលទេអ្នកមីង???

ខៈ

ចាសនិយាយទៅគឺនៅក្នុងជំនាន់នឹងគឺគាត់ជាអ្នកកាន់ខាងម្ហូបហើយដល់ពេលក្រោយមកនឹងគឺគេបានចាប់គាត់ឪពុករបស់ខ្ញុំនឹងទៅបរប៉ៃលិនហើយនៅពេលដែលចាប់គាត់ទៅបរប៉ៃលិននឹងគឺគាត់ឡើងស្គមពីព្រោះអីនឹងផ្ទះរបស់យាយរបស់ខ្ញុំនឹងគឺមានកូនសុទ្ធប្រុសចឹងហាសហើយដល់ពេលចឹងគឺគេបានយកទៅធ្វើបរប៉ៃលិនហើយគឺគាត់បានចាប់យកទៅធ្វើបេប៉ៃលិនចឹងហាសចាសហើយនៅពេលដែលគាត់បានត្រឡប់មកវិញនឹងគឺគាត់ចាញ់តែម្តងហាសចាសហើយគាត់ស្គប់ជិតស្លាប់ជិតរស់ចឹងហាសចាសហើយសំរាប់គេបានចាប់គាត់ធ្វើទាហ៊ានចឹងហាសហើយនៅពេលដែលទៅមកកពីនោះវិញនឹងគឺយើងបានលក់របបរបស់នឹងទៅមើលជំងឺអស់សំរាប់ជំនាន់នឹងហាសចាសហើយសំរាប់ជំនាន់នឹងនៅពេលដែលចាញ់នឹងគឺគ្មានថ្នាំដូចល្វូវនឹងណាចាសហើយដល់ពេលដែលចាញ់ចឹងគឺគាត់ស្គប់ហើយនឹងរងាយហើយនៅពេលដែលយើងបានលក់របបរបស់ទាំងអស់ហើយចឹងគឺគាត់បានជាបានចឹងហាសចាសហើយសំរាប់ជំនាន់នឹងគឺគាត់បានស្គប់ហើយយើងនឹងបានដឹងតែប៉ុននឹងចឹងហាសក្រៅពីនឹងអត់ដឹងអ្វីទៀតនោះទេចាសហេហេហេហេចាសនិយាយទៅគឺខ្ញុំនិយាយតាមគាត់ប្រាប់យើងចឹងដែលចឹងហាសនិយាយទៅមិនមែនមកស្មើបយកទៅធ្វើអ្វីការងារនឹងប្រវត្តិរបស់ខ្ញុំនិយាយទៅគឺខ្ញុំខ្លាចណាស់ណាហេហេហេហេចាសនិយាយទៅគឺយើងចេះតែគិតចឹងទៅណាចាស៕

កៈ

បាទនិយាយទៅកុំបារម្ភអីអ្នកមីងហើយចឹងសំរាប់អ្នកមីងអ្នកមីងមានអារម្មណ៍យ៉ាងមិចដែលនៅពេលដែលអ្នកមីងកើតមកអត់ទាន់ជំនាន់រំដោះហើយសំរាប់អ្នកមីងហើយអត់សូវមានភាពពិបាក់ដូចជំនាន់ឪពុកហើយនឹងម្តាយរបស់អ្នកមីងចឹងអ្នកមីងមានអារម្មណ៍យ៉ាងមិចដែលទៅអ្នកមីង???

ខៈ

ចាសសំរាប់ខ្ញុំគឺខ្ញុំមានអារម្មណ៍សប្បាយចិត្តហើយសប្បាយក៏សប្បាយហើយក៏យើងនឹងបានគិតថាប្រសិនជាយើងបានកើតនៅក្នុងជំនាន់ពោលពតនឹងថាតើយើងនឹងបានរស់ដូចគេ

ដែលរឺទេយើងគិតចឹងហាសចាសហើយប្រសិនជាយើងបានកើតនៅក្នុងជំនាន់នឹងគឺយើងប្រហែលជាមិនរស់នោះទេចាសហើយសំរាប់ក្មេងជំនាន់លូវនឹងគឺជំនាន់នឹងនិយាយទៅសប្បាយចិត្តនិយាយទៅមិនសប្បាយចិត្តយ៉ាងមិចគឺគាត់ខំពរពោះយើងហើយដល់ពេលដែលជិតដល់រំដោះថ្មីថ្មីនឹងគឺយើងគ្មានសំរាប់ហូបសំរាប់ជំនាន់នឹងហើយសំរាប់ដល់ពេលនឹងគឺយើងនឹងក៏អត់សូវមានដែលចឹងហាសចាសហើយដល់ពេលយូរយូរទៅបានគាត់បានរកស៊ីចឹងហាសចាសហើយនៅពេលដែលគាត់បានរកស៊ីនឹងគឺជំនាន់នឹងកូនរបស់គាត់មាន៥នាក់ដែលចឹងហាសចាសហើយដល់ពេលនឹងគឺគេចាប់គាត់ទៅបរនៅប៉ៃលិនចឹងហាសហើយគេបាននិយាយថាគឺគេបានអោយគាត់បានធ្វើជាទាហ៊ានចឹងហាសហើយនៅពេលដែលគាត់បានទៅនឹងគឺគាត់ទាំងអស់នឹងបានឈឺគ្រាប់គ្នាហើយដល់ពេលដែលជិតរំដោះហើយចឹងបានយើងនឹងចេះតែរកស៊ីបានតិចតិចចឹងទៅពីព្រោះអីនឹងសំរាប់ជំនាន់ពីដើមនឹងសំរាប់លោកយាយរបស់ខ្ញុំនឹងគឺគាត់គឺជាលក់ឈូកហើយគាត់លក់ចឹងហាសតែលោកយាយរបស់ខ្ញុំនឹងគឺគាត់ស្លាប់ពីព្រោះអីនឹងគឺគាត់បានលិចទូកនៅជប៉ុនហើយគាត់បានលិចទូកដោយសារគាត់បានរកស៊ីហើយបានលិចទូកចឹងហាសចាសហើយនៅពេលដែលលិចទូកនឹងគឺគាត់ព្យាលយាមឡើកទូកវិញតែគាត់ក្រោកពីទូកនឹងមិនរួចក៏បានស្លាប់ទៅចាសហើយសំរាប់គាត់រស់មិនសូវបានយូរដោយសារគាត់ជាអ្នករកស៊ីចឹងហាសចាស៕

ក៖
បាទហើយចឹងបានន័យថាសំរាប់ជំនាន់នឹងគឺលោកតារបស់អ្នកមីងគាត់គឺជាអ្នកមីងរកស៊ីទូកមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគាត់បានរកស៊ីខាងទូកដឹងជញ្ជូលទៅភ្នំពេញចាសសំរាប់ជំនាន់នឹងគឺគាត់គឺជាមនុស្សធូធារចឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់ជំនានន់នឹងលោកតារបស់អ្នកមីងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់លោកតារបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា តា សុខ ៕

ក៖
បាទហើយប្រសិនជាលោកតារបស់អ្នកមីងគាត់នៅរស់គាត់មានអាយុប៉ុន្មានឆ្នាំហើយទៅអ្នកមីង???

ខ៖ ចាសហើយប្រសិនជាគាត់នៅរស់នឹងចូលជាង ៩០ រឺក៏ ១០០ឆ្នាំ
ហើយចាសពីព្រោះអីនឹងសំរាប់ជំនាន់នឹងគឺគាត់មានអាយុច្រើនហើយចឹងហាសចាសហើយសំរាប់កាល់នឹងគឺម្តាយរបស់ខ្ញុំនឹងគឺគាត់បាននិយាយប្រាប់ខ្ញុំចឹងហាសចាសពីព្រោះអីនឹងកាល់ដែលគាត់បានស្លាប់នឹងគឺគាត់មានអាយុ ៧៥

ឆ្នាំហើយប្រសិនជាយើងបាននិយាយលូវលូវនឹងដែលចឹងហាសចាសនឹងគឺគាត់បានលឺប្រាប់ខ្ញុំដែលហាសចាសនិយាយទៅសំរាប់គាត់គឺប្រហែលជា ១០០
ឆ្នាំជាហើយចឹងហាសចាស៕

កៈ
បាទហើយចឹងបានន័យថាសំរាប់ជំនាន់នឹងអ្នកមីងបានកើតជំនាន់លោកតាមែនដែលទេអ្នកមីង???

ខៈ
ចាសនិយាយទៅគឺខ្ញុំបានកើតទាន់ដែលចឹងហាសក៏ប៉ុនតែនៅពេលដែលម្ដាយរបស់ខ្ញុំគាត់បានឈឺពោះហើយគាត់បានពរពោះខ្ញុំនឹងគឺថាគាត់បានទៅយកឰ្យងមកចឹងហាសហើយគាត់បានយកម្ដាយរបស់ខ្ញុំទៅអាំងភ្លើងអាំងអីចឹងហាសហើយក៏បានហៅឈ្មោះអីចឹងហាសនឹងគឺខ្ញុំបាននិយាយតាមម្ដាយរបស់ខ្ញុំដែលហោហោហោហោហើយនៅពេលដែលគាត់បានឈឺពោះនឹងគឺខ្ញុំបានរកឰ្យងយកមកអាំងភ្លើងហើយចឹងនៅពេលដែលគាត់បានស្លាប់នឹងគឺខ្ញុំបានកើតមកអស់រយះពេល២ខែចឹងហាសនឹងសំរាប់កាល់ដែលគាត់បានស្លាប់ចឹងហាសចាស៕

កៈ
បាទហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើអ្នកមីងសព្វថ្ងៃនឹងអ្នកមីងបានប្រកបមុខរបបអ្វីដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់សព្វថ្ងៃនឹងគឺខ្ញុំបានប្រកបមុខរបបត្បាញ់ចឹងហាសចាសគឺខ្ញុំបានត្បាញ់សំពត់ហើយនឹងសូត្រចឹងហាស៕

កៈ
បាទហើយសំរាប់អ្នកមីងបានប្រកបមុខរបបនឹងអស់រយះពេលប៉ុន្មានឆ្នាំហើយចឹងទៅអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំបានប្រកបមុខរបបនឹងអស់រយះពេល ៤ ឆ្នាំ
ហើយនឹងប្រសិនជាខ្ញុំបានគិតចឹងហាសហើយនិយាយទៅគឺខ្ញុំបានធ្វើវាយូរហើយចឹងហាសហើយគិតទៅ ៤ រឺក៏៥ឆ្នាំតាមដែលខ្ញុំបានគិតចឹងហាសចាស៕

កៈ
បាទហើយសំរាប់ការត្បាញ់នឹងសំរាប់អ្នកមីងបានចេះដោយខ្លួនឯងរឺក៏មាននាក់ណាដែលបានមកបង្រៀនអ្នកមីងដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅសំរាប់ពីមុននឹងគឺខ្ញុំបានត្បាញ់ជាមួយនឹងអំបោះចឹងហាសគឺជាអំបោះធម្មតាចឹងហាសចាសហើយសំរាប់ការត្បាញ់សូត្រនឹងកឹយើងនឹងមិនដែលបានត្បាញ់នោះទេតែគេនាក់ដែលគេបានធ្លាប់ត្បាញ់នឹងគឺគេបានប្រាប់យើងចឹងទៅហើយយើងបានយកមកហើយយើងបានចេះតាមគេចឹងទៅហាសចាស៕

ក៖
បាទហើយចឹងបានន័យថាអ្នកមីងចេះដោយសារគេបានប្រាប់អ្នកមីងមែនដែលទេអ្នកមីង???

ខ៖ ចាសគឺខ្ញុំចេះដោយសារគេបានប្រាប់ខ្ញុំចាស៕

ក៖ បាទហើយចឹងបានន័យថាសំរាប់អ្នកមីងឆ្លាតមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគ្មានគ្រូនោះទេគ្រាន់តែគេបានប្រាប់ចឹងទៅគឺខ្ញុំបានចេះចឹងហាសចាសពីព្រោះអីនឹងគឺយើងពីមុននឹងគឺយើងនឹងបានធ្លាប់ត្បាញ់ដែលតែវាគ្រាន់តែជាអំបោះចឹងហាសហើយសំរាប់ត្បាញ់នឹងគឺវាមានរបៀបផ្សេងចឹងហាសតែគ្រាន់តែថាការត្បាញ់នឹងគឺវាដូចគ្នាចឹងហាសហើយនៅពេលដែលគេបានប្រាប់យើងនឹងបានតិចទៅគឺយើងអាចយល់បានចឹងហាសចាស៕

ក៖
បាទហើយចឹងខ្ញុំឆ្ងល់បន្តិចថាសំរាប់អំបោះហើយនឹងសូត្រនឹងវាមានភាពខុសគ្នាយ៉ាងមិចដែលទៅអ្នកមីងដែលពេលដែលបានត្បាញចេញមកចឹងហាសអ្នកមីង???

ខ៖
ចាសសំរាប់អំបោះនឹងគឺយើងនឹងអាចប៉ះបានហើយនឹងច្រលុកទឹកបានចឹងហាសហើយសំរាប់សូត្រវិញគឺយើងមិនអាចដាក់ទឹកបាននោះទេគឺគេសុទ្ធតែមានថ្នាំចឹងហាសចាសហើយនៅពេលដែលវាបានប៉ះនឹងគឺវាមិនដូចជាក្រមារធម្មតានោះទេចាសហើយសំរាប់អំបោះធម្មតានឹងគឺយើងអាចបោកគុតហើយសំរាប់មួយនឹងគឺគេមានថ្នាំសំរាប់គេបោកចឹងហាសបពីព្រោះអីនឹងគឺវាមានជាតិសសៃសូត្រចឹងហាសចឹងហើយវាមិនអាចបោកទឹកធម្មតាបាននោះទេចាសហើយសំរាប់ការណែនាំរបស់គេនឹងគឺយើងអាចធ្វើខូចសំពតរបស់គេបានចឹងហាសចាសហើយសំរាប់កន្លែងនឹងក៏វាមានរាងហើយសំរាប់រាងនឹងក៏វាមានខុសគ្នាហើយនឹងតំម្លៃនឹងក៏ខុសគ្នាដែលចឹងហាសចាស៕

ក៖ បាទហើយសំរាប់រាងហើយនឹងតំម្លៃនឹងខុសគ្នាយ៉ាងដូចម្តេចដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់ក្រមាររបស់យើងនឹងគឺវាមានតំម្លៃតែ ៦០០០រីក៏
៧០០០អីចឹងហាសចាសហើយសំរាប់ស្លូត្រនឹងគឺមានតំម្លៃ៣០ដុល្លារីក៏បាន៤០ដុល្លាចឹងហាសចាសហើយនិយាយទៅគឺជនជាតិគេគឺជាអ្នកទិញចឹងហាសតែសំរាប់ជនជាតិខ្មែរគាត់អត់បានទិញនោះទេចាសពីព្រោះអីនឹងគឺយើងបានបាញ់ទឹកនឹងបានស្មើចឹងហាសចាសហើយយើងបានតាំងហើយនៅពេលជនជាតិគេបានចុះមកចឹងគឺគេបានទិញចឹងហាសនិយាយទៅគឺសុទ្ធតែមានជនជាតិចឹងហាសចាសគឺអត់មានខ្មែរទិញនោះទេចាសហើយសំរាប់គេដែលជាអ្នកមានហើយគេមានលុយទិញហើយនឹងបានប្រើបានចឹងហាសចាសហើយសំរាប់អ្នកដែលអត់គឺគាត់អត់បានទិញទេពីព្រោះអីនឹងគឺ៣០ដុល្លា៤០ដុល្លាហើយនិយាយទៅគឺវាខុសគ្នាឆ្ងាយខ្លាំងណាស់ចាសនឹងសំរាប់ក្រមារខុសគ្នាចឹងហាសចាស៕

ក៖
បាទហើយចឹងអរគុណាច្រើនអ្នកមីងហើយចឹងសំរាប់សព្វថ្ងៃនឹងអ្នកមីងមានបទពិសោធន៍អ្វីខ្លះដែលមានភាពសប្បាយចិត្តជាមួយនឹងក្រុមគ្រួសាររបស់អ្នកមីងថាតើអ្នកមីងអាចចែកចាយពីភាពបច្ចុប្បន្នជាមួយនឹងក្រុមគ្រួសាររបស់អ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅសំរាប់អាជីបរបស់យើងនឹងគឺមិនទាន់បានទៅដោយរលូនចឹងហាសនិយាយទៅដូចថានៅពេលដែលយើងចាសចឹងគឺគេមិនបានយកយើងនោះទេតែសំរាប់ការងារមួយនេះប្រសិនជាយើងមិនចង់ធ្វើក៏បានដែលចឹងហាសហើយប្រសិនជាយើងនឹងនៅធ្វើវាបានយើងចេះតែធ្វើវាចឹងទៅហាសចាសពីព្រោះអីនឹងល្ងូវនឹងគឺគេបានរកតែអ្នកដែលនៅក្មេងក្មេងចឹងហាសហេហេហេតែសំរាប់មួយនេះវាគឺជាអាជីបប្រចាំថ្ងៃរបស់យើងរាល់ថ្ងៃចឹងហាសចាសនិយាយទៅគឺវាបន្ទាបបន្សំចឹងហាសហើយប្រសិនជាអោយសល់នឹងគឺយើងមិនសល់នោះទេគ្រាន់តែបានមួយចាយចាយចឹងហាសចាសនិយាយទៅគឺអត់សល់នោះទេពីព្រោះអីនឹងគឺស្លូត្រនឹងវាមានតំម្លៃចឹងហាសចាស៕

ក៖
បាទហើយចឹងបានន័យថាសំរាប់ស្លូត្រនឹងអ្នកមីងបានទិញមកពីគេមែនដែលទេអ្នកមីង???

ខ៖
ចាសសំរាប់ស្លូត្រនឹងគឺខ្ញុំបានទិញពីគេចឹងហាសតែសំរាប់ល្ងូវនឹងគឺគេសុទ្ធតែស៊ីឈ្នួលគេដែលចឹងហាសចាសពីព្រោះអីនឹងនៅពេលដែលយើងនឹងធ្វើដោយខ្លួនឯងនឹងគឺយើងមិនជាស្ងូវបានចំណេញនោះទេគឺវាគ្រាន់តែបានដើមមកវិញចឹងហាសចាសហើយប្រសិនខ្លះគឺយើងអាចខាតទៀតចឹងហើយវាមិនស្ងូវចំនេញចឹងហាសចាសហើយនៅពេលដែលថ្លៃចឹងសំរាប់ទី១នឹងគឺគេមិនបានធ្វើគឺគេបានទៅស៊ីឈ្នួលដោយខ្លួនឯងតែម្តងចឹងហាសចាសហើយនៅពេលដែលយើងនឹងបានទៅស៊ីឈ្នួលនឹងគឺយើងដឹងតែកាត់ហើយនឹងបានយកលុយនឹងពីគេតែម្តងចឹងហាសចាស៕

កៈ
បាទហើយចឹងសំរាប់មិនព្រមចញ្ចឹមដង្កូវនាងនឹងដើម្បីយកសូត្រនឹងតែម្តងទៅអ្នកមីង???

ខៈ
ចាសនិយាយទៅគឺវាមានភាពពិបាកខ្លះណាស់ចាសពីព្រោះអីនឹងសំរាប់យើងគ្មានបទពីសោធន៍ខាងនឹងគឺវាមានភាពពិបាក់ទំរាំតែយើងធ្វើបានជាសសៃសូត្រនឹងមិនងាយនោះទេចាសនឹងសំរាប់ពីមុនមកចឹងហាសហើយសំរាប់យើងដូចទទេទទេនឹងគឺវាមិនងាយស្រួលនោះទេនិយាយទៅគឺវាមានតំណាក់កាល់របស់វាចឹងហាសហើយវាមិនអាចចេញជាសសៃសូត្រមកភ្លែមភ្លែមមកបានងាយនោះទេចាសនិយាយទៅគឺវាត្រូវការឆ្លងកាត់ច្រើនហើយសំរាប់យើងក៏ត្រូវប្រើឧបករណ៏នឹងក៏វាមានច្រើនដែលចឹងហាសចាសនិយាយទៅដល់តែយើងនឹងមានកន្លែងធ្វើខាងកសិកម្មសំរាប់ចិញ្ចឹមតែម្តងហាសចាសនឹងបានកើតនឹងហើយប្រសិនជាយើងធម្មតាយើងគ្រាន់តែស៊ីឈ្នួលតាមធម្មតាចឹងទៅហាសចាសហើយសំរាប់អ្នកដែលគេចេះគេបានច្រើនចឹងទៅសំរាប់អ្នកដែលគេអត់បានចេះគេធ្វើតាមធម្មតាចឹងទៅហាសចាសនិយាយទៅគឺវាមានភាពពិបាក់ដែលចឹងហាសមិនមែនបានស្រួលស្រួលនោះទេចាស៕

កៈ
បាទហើយចឹងមិនមែនវានៅពេលដែលយើងចិញ្ចឹមវាទៅវាបញ្ចេញសូត្រអោយយើងនឹងស្រួលស្រួលនោះទេមែនដែលទេអ្នកមីងគឺមានតាមដំណាក់កាល់របស់វាមែនដែលទេអ្នកមីង???

ខៈ
និយាយទៅនៅពេលដែលយើងនឹងបានយកមកនឹងគឺថាយើងយកហាហើយយើងយកមកចងហើយនឹងស្ងោរហើយនឹងគឺយើងទៅជាររៃហើយនៅពេលដែលររៃហើយចឹងបានយកទៅធ្វើជាប៉ោយជាអំបោះហើយនឹងបានអោយបាយអោយអីទៀតចឹងហាសបានវាចេញជាសសៃសូត្រហាសចាសនិយាយទៅវាមានច្រើនណាស់មិនមែនស្រួលនោះទេចាសទាល់តែយើងនឹងបានទៅមើលនៅក្នុងចំការស្មេហ៏នឹងបានដឹងចឹងហាសចាស៕

កៈ បាទនិយាយទៅគឺខ្ញុំអត់ដែលបានចូលនោះទេបាទ៕

ខៈ
ហាសនិយាយទៅអត់ដែលបានចូលទេមែនដែលទេហើយប្រសិនជាចូលលេងនៅចំការស្នេហ៏នឹងគឺអស់តែ ២០០០រនោះទេហើយនៅពេលដែលយើងចូលទៅអស់ ២០០០រនឹងគឺយើងចូលមើលទៅអំពីរបៀបដែលគេបានចិញ្ចឹមសូត្រចឹងហាសចាសនឹងគឺនៅក្នុងនឹងគឺគេបានចិញ្ចឹមសត្វនឹងហើយគេបានត្បាញអំពីសូត្រនឹងហាសចាសហើយគេបានដាក់តាផ្ទះចឹងហើយយើងសុំគេមើលចឹងទៅហើយសំរាប់ខ្ញុំនឹងគឺគេបានហៅធ្វើនៅទីនោះដែលតែខ្ញុំអត់ទៅគឺខ្ញុំសុទ្ធចិត្តធ្វើនៅជិតហើយនឹងខ្ជិលនឹងជិះម៉ូតូហើយយើងបានលុយខ្លះសំរាប់

ទុក្ខអោយកូនរបស់យើងដែលចឹងហាសចាសហើយសំរាប់របៀបដែលគេបានចិញ្ចឹមសូត្រហើយនឹងដង្កូវនាងនឹងគឺនៅទីកន្លែងនឹងទាំងអស់ចឹងហាសចាសហើយប្រសិនជាយើងចង់សួរអីនឹងគឺយើងសួរគេទៅគេនឹងប្រាប់យើងហើយចាស៕

កៈ
បាទហើយចឹងបានន័យថាសំរាប់នៅក្នុងចំការស្ទេហ៍នឹងគឺគេបានចិញ្ចឹមដង្កូវនាងដែលមែនដែលទេអ្នកមីង???

ខៈ
ចាសគឺគេបានចិញ្ចឹមហើយចេញជាសសៃសូត្រចឹងមកចាសនិយាយទៅសំរាប់ក្រមារនឹងគឺគេបានធ្វើចេញពីស្នារដៃរបស់កូនខ្មែរយើងពិតពិតតែម្តងហាសចាសហើយក៏អត់បានយកពីខាងក្រៅមកដែលចឹងហាសចាសហើយសំរាប់ខ្ញុំគឺខ្ញុំបានត្បាយទាំងក្នុងហើយនឹងទាំងក្រៅចឹងហាសចាសតែគ្រាន់តែគេបានឆ្នៃជាព័ណផ្សេងហើយនឹងម៉ូតផ្សេងចឹងទៅតែសំរាប់សសៃសូត្រនឹងគឺគេបានយកចេញមកពិតពិតតែម្តងគឺគ្មានការយកចេញពីខាងក្រៅមកនោះទេចាសហើយសំរាប់ទាំងអស់នឹងគឺវាត្រូវការពេលវេលាច្រើនហើយនឹងកំលាំងនឹងក៏វាច្រើនដែលចឹងហាសចាសទំរាំតែបានចេញជាសូត្រចឹងហាសចាស៕

កៈ
បាទឡូយមែនទែនអ្នកមីងបាទហើយចឹងសំរាប់ថ្ងៃនឹងខ្ញុំសប្បាយចិត្តមែនទែនអ្នកមីង???

ខៈ
ចាសបើលមិនសប្បាយចិត្តយ៉ាងមិចពីព្រោះអីនឹងនិយាយពីប្រវត្តិរបស់ខ្ញុំអស់ហើយនឹងហេហេហេ៕

កៈ
បាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំពិតជាសប្បាយចិត្តមែនទែមអ្នកមីងដែលបានជួបជាមួយនឹងអ្នកមីងហើយបានអ្នកមីងផ្តល់ឧកាសហើយនឹងបានពិក្សាហើយនឹងផ្តល់ពីជីវហើយនឹងផ្តល់ពីប្រវត្តិរបស់អ្នកមីងពិតដែលនៅជំនាន់បច្ចុប្បន្នហើយនឹងហើយដែលអ្នកមីងបានកើតនៅជំនាន់ពោលពតហើយចឹងខ្ញុំចង់សួរសំណួរមួយចុងក្រោយទៅកាន់អ្នកមីងថាតើអ្នកមីងមានអ្វីផ្តែលផ្តាំទៅកាន់កូនចៅរបស់អ្នកមីងដែលរឺទេនៅពេលដែលគាត់បានលឺសំលេងរបស់អ្នកមីងសំរាប់អ្នកមីងចង់ផ្តែលផ្តាំទៅកាន់គាត់ដើម្បីអោយគាត់ខំប្រឹងប្រែរៀនសូត្រហើយនឹងខំប្រឹងជួយឪពុកហើយនឹងម្តាយសំរាប់អ្នកមីងមានអ្វីផ្តែលផ្តាំទៅកាន់គាត់ដែលរឺទេអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំគ្រាន់តែផ្តាំទៅកាន់កូនរបស់ខ្ញុំថាសំរាប់ទៅថ្ងៃក្រោយទៅប្រសិនជាអត់មានពីខ្ញុំទៅគឺខ្ញុំចង់អោយគាត់រៀនអោយបានច្រើនចឹងហាសចាសហើយនឹងអោយមានការងារដែលល្អល្អធ្វើចឹងហាសកុំអោយដូចជាខ្ញុំអត់មានការងារសំរាប់ធ្វើអត់មានអ្វីសំរាប់ចិញ្ចឹមកូ

នចឹងហាសចាសគឺចង់អោយគាត់រៀនអោយបានច្រើនកុំអោយគាត់យកពេលវេលាណាដែលសល់អត់មានប្រយោជន៍ចឹងហាសគឺចង់អោយគាត់ខំប្រឹងប្រែរៀនចឹងទៅហាសចាសហើយសំរាប់ខ្ញុំមានសម្តតភាពរបស់ខ្ញុំមានប៉ុនណាគឺខ្ញុំអោយកូនរបស់ខ្ញុំនឹងបានរៀនប៉ុននឹងចឹងហាសចាសហើយសំរាប់ខ្ញុំមិនអាចអោយកូនរបស់ខ្ញុំនឹងឈប់រៀនបាននោះទេចាសគឺខ្ញុំចង់អោយគាត់រៀនបានចេះដឹងហើយនឹងមានការងារដែលល្អធ្វើចឹងទៅហើយកុំអោយពួកវានឹងមានភាពពិបាកដូចយើងនឹងលូវលូវចឹងហាសចាសពីព្រោះអីនឹងសំរាប់កូនរបស់គេនឹងគឺគេបានទៅរៀននឹងសាលារៀនល្អល្អនឹងគឺយើងគ្មានសម្តតភាពដូចគេទេគឺយើងមានតែរៀនបានតាមធម្មតាចឹងហាសចាសគឺយើងគ្មានសម្តតភាពអោយរៀនសាលាដែលមានតំម្លៃថ្លៃចឹងហាសចាសហើយសំរាប់គ្មានផ្តាំអ្វីទៀតនោះទេចាសហេហេហេហេ៕

ក៖
បាទហើយចឹងអរគុណច្រើអ្នកមីងហើយចឹងអ្នកមីងអត់ហើយមែនដែលទេអ្នកមីងអត់ចង់បន្ថែមអីតិចទៀតនោះទេមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺអស់ហើយគឺមានតែប៉ុននឹងចឹងហាសគ្មានអ្វីទៀតនោះទេចាសពីព្រោះអីនឹងសំរាប់ប្រវត្តិរបស់ខ្ញុំនឹងគឺមានតែប៉ុននឹងចឹងហាសចាសហេហេហេ៕

ក៖
បាទហើយចឹងកុំភ្លេចរៀនអោយបានច្រើនលីដែលរឺទេចឹងអរគុណច្រើនអ្នកមីងហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំមានតែប៉ុននឹងសំរាប់អ្នកមីងហើយសំរាប់ខ្ញុំពិតជាសប្បាយចិត្តមែនទែនហើយក៏ខ្ញុំចង់និយាយថាអរគុណអ្នកមីងម្តងទៀតសំរាប់ការផ្តល់យោលបល់ហើយជាពិសេសនឹងគឺអំពីជីវិតពិតរបស់អ្នកមីងនាពេលបច្ចុប្បន្ននេះចឹងហាសអ្នកមីង???

ខ៖
ចាសហើយចឹងនៅពេលដែលដើរសំភាសន៍គេគ្រាប់គ្នាចឹងដែលមែនដែលទេហើយគេបានឆ្លើយចឹងដែលមែនដែលទេ???

ក៖
បាទនិយាយទៅគឺគេបាននិយាយផ្សេងពីគ្នាពីព្រោះអីនឹងសំរាប់ជីវិតរបស់គេគឺផ្សេងផ្សេងគ្នាចឹងហាសនឹងហើយដោយសារជីវិតរបស់គេមួយមួយគឺមិនបានដូចគ្នានោះទេដែលនៅក្នុងជំនាន់ពោលពតចឹងហាសហើយសំរាប់អ្នកខ្លះនឹងគឺគេបាននៅក្នុងកងចលត័ដែលគេមានម្ហូបអាហារគ្រាប់គ្រាន់ចឹងទៅហើយសំរាប់អ្នកខ្លះនឹងគឺគេបាននៅក្នុងកងចលត័ដែលអត់មានម្ហូបគេមិនសូវជាច្រើនចឹងទៅគឺគេបានរស់នៅផ្សេងផ្សេងគ្នាចឹងទៅហាសហើយសំរាប់អ្នកខ្លះនឹងគឺគេបានធ្វើការងារដែលស្រួលចឹងទៅហើយសំរាប់អ្នកខ្លះទៀតគឺគេបានអោយធ្វើការងារដែលពិបាកចឹងទៅចឹងហើយសំរាប់ជីវិតរបស់ពួកគាត់គឺមិនបានដូចគ្នានោះទេបាទចឹងជាមូលហេតុខ្ញុំចុះមកដើម្បីចង់ដឹងចឹងហាសអ្នកមីង???

ខ៖ ចាសហើយសំរាប់ចុះមកនឹងគឺគ្រាន់តែសួរប៉ុននឹងទេមែនដែលទេ???

ក៖
បាទគឺគ្រាន់តែប៉ុននឹងហោហោហោចឹងអត់អីទេអ្នកមីងហើយសំរាប់ថ្ងៃនឹងគឺខ្ញុំមានតែប៉ុននឹងអ្នកមីងហើយចឹងប្រហែលជាខ្ញុំអស់ហើយសំរាប់ថ្ងៃនឹងហើយអរគុណច្រើនអ្នកមីងហើយចឹងខ្ញុំជំរាបលាអ្នកមីង៕